# មេរៀនទី៥០៖ រ៉ាហាបជួយសង្គ្រោះអ្នកស៊ើបការ

## យ៉ូស្វេ ២៖១-២៤

**មេរៀន** ( *យូធូបលីង* )៖ https://youtu.be/ePTa_Opa0KA

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/REECEV9xYT8

**គោលបំណង៖** ព្រះចង់ឲ្យយើងស្មោះត្រង់ក្នុងសេចក្ដីជំនឿដើម្បីទទួលបាននូវសេចក្ដីសង្គ្រោះ

**ខគម្ពីរចងចាំ៖ ហេព្រើ ១១៖៦** *"តែបើឥតមានសេចក្ដីជំនឿទេ នោះមិនអាចនឹងគាប់ដល់ព្រះហឫទ័យព្រះបានឡើយ ដ្បិតអ្នកណាដែលចូលទៅឯព្រះនោះត្រូវតែជឿថា មានព្រះមែន ហើយថាទ្រង់ប្រទានរង្វាន់ដល់អស់អ្នកដែលស្វែងរកទ្រង់។"*

**ចំរៀង** ( *យូធូបលីង* )៖

១. ព្រះអម្ចាស់យើងល្អណាស់ https://youtu.be/JUMy8rZvqjY

២. បាបខ្ញុំអស់ហើយ https://youtu.be/zosjd2E8cmE

៣. ខ្ញុំទុកចិត្តដល់ព្រះយេស៊ូវ https://youtu.be/Vq_yln2huAM

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ដ « តើព្រះអង្គស្មោះត្រង់ប៉ុណ្ណា ?»



**សំភារៈដែលត្រូវការ៖** ចានគោមកែវថ្លា ដុំថ្មធំមួយចំនួន ដី ទឹក

១.សួរកុមារថាតើព្រះស្មោះត្រង់ចំពោះយើងប៉ុណ្ណា។ នេះគឺមានន័យថាព្រះអង្គទ្រង់មិនដែលចាកចេញ ឬបោះបង់យើងចោលនោះឡើយ។ សូមដាក់ថ្មចូលចាននៅរាល់ពេលដែលកុមារម្នាក់និយាយពីរបៀប ដែលព្រះជាម្ចាស់បង្ហាញពីសេចក្ដីស្មោះត្រង់របស់ទ្រង់។ ពេលដែលដាក់ថ្មពេញចានហើយ សូមសួរកុមារថាតើចានដាក់ថ្មពេញឬនៅ?

២. នៅពេលកុមារឆ្លើយថា " បាទ/ចាស ចានពេញហើយ" ពេល ដែលពួកគេ គិតថា ព្រះមិនបានស្មោះត្រង់ជាមួយយើងនោះទេ សូមពន្យល់កុមារថា ព្រះនៅ តែបន្តភាពស្មោះត្រង់របស់ទ្រង់ជាមួយយើង។ បន្ទាប់មកយកដីមកចាក់ នៅតាមចន្លោះថ្ម។ នៅពេលចានបានពេញទៅដោយថ្មនិងដីសូមសួរកុមារៗថាតើចានពេញឬនៅ?

៣. នៅពេលដែលកុមារឆ្លើយថា " បាទ/ចាស ចានពេញហើយ " សូមពន្យល់កុមារម្ដងទៀតថា ភាពស្មោះ ត្រង់របស់ព្រះជាម្ចាស់មិនប្រែប្រួលឡើយ។ បន្ទាប់មកចាក់ទឹកចូលចានរហូតទាល់តែដល់ទឹកពេញចាន។

៤.ពន្យល់កុមារថា ព្រះនឹងមិនដែលចាកចោល ឬបោះបង់ពួកគេចោលឡើយ។ នោះមានន័យថា ព្រះជាម្ចាស់ស្មោះត្រង់។ នៅពេលយើងទុកចិត្តលើព្រះយើងក៏ស្មោះត្រង់ដែរ។ ពេលនេះប្រហែលជាមានរឿងដែលពិបាកកំពុងតែកើតឡើងនៅក្នុងជីវិតពួកគេ។ ប្រហែលជាពួកគេឆ្ងល់ថា តើព្រះពិតជានៅទីនោះ

មែនដែរឬទេ ឬក៏តើព្រះអង្គពិតជាបានយកចិត្តទុកដាក់ចំពោះពួកគេមែនដែរឬទេ? សូមលើកទឹកចិត្តពួកគេឱ្យជឿថា ព្រះតែងតែគង់នៅជាមួយពួកគេជានិច្ច។

## ៤. ការណែនាំមេរៀន

ព្រះតែងតែស្មោះត្រង់ចំពោះយើង។ នេះគឺមានន័យថាយើងអាចទុកចិត្តទ្រង់បានព្រោះព្រះអង្គមិនដែលផ្លាស់ប្តូរសេចក្តីស្រឡាញ់របស់ទ្រង់ចំពោះយើងឡើយ។ ព្រះអង្គក៏ចង់ឲ្យយើងស្មោះត្រង់ផងដែរ។ តើភាពស្មោះត្រង់មានន័យយ៉ាងដូចម្តេច? គឺមានន័យថា ត្រូវធ្វើនូវអ្វីដែលយើងត្រូវធ្វើ ហើយធ្វើតាមព្រះជាម្ចាស់បើទោះបីជាវាពិបាកយ៉ាងណាក៏ដោយ។ ភាពស្មោះត្រង់មានន័យថា យើងអាចទុកចិត្តបានដើម្បីធ្វើនូវអ្វីដែលយើងគួរធ្វើ ទោះបីជាគ្មាននរណាម្នាក់ឃើញ ហើយទោះបីជាយើងមិនមានអារម្មណ៍ធ្វើវាក៏ដោយ។ ការមកព្រះវិហាររៀងរាល់សប្តាហ៍បង្ហាញពីភាពស្មោះត្រង់ចំពោះព្រះ។ វាដូចជាការដែលយើងរាប់អានមិត្តភ័ក្តិ បើទោះបីជាអ្នកដទៃមិនចូលចិត្តមិត្តភក្តិរបស់យើងក៏ដោយ ហើយការរក្សាពាក្យសន្យារបស់អ្នកក៏បង្ហាញពីភាពស្មោះត្រង់ផងដែរ។ ភាពស្មោះត្រង់របស់យើងធ្វើឱ្យព្រះមាន ព្រះហឫទ័យរីករាយ។ ថ្ងៃនេះ យើងនឹងរៀនអំពីស្ត្រីម្នាក់ដែលស្មោះត្រង់នឹងព្រះជាម្ចាស់។ តោះយើងទៅស្វែងយល់ ជាមួយគ្នាថាតើនាងបានធ្វើអ្វី!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ពេលដែលយ៉ូស្វេបានក្លាយទៅជាអ្នកដឹកនាំរបស់ជនជាតិអ៊ីស្រាអែល គាត់បានបញ្ជូនអ្នកស៊ើបការ២នាក់ឲ្យទៅកន្លែងមួយដែលមានឈ្មោះថាយេរីខូ។ អ្នកស៊ើបការរបស់យ៉ូស្វេបានលបចូលទៅក្រុងយេរីខូ ដើម្បីពិនិត្យមើលថា តើសត្រូវរបស់ពួកគេមានកំលាំងខ្លាំងប៉ុនណា។ អ្នកស៊ើបការរបស់យ៉ូស្វេចូលទៅក្នុងក្រុងយេរីខូយ៉ាងឆាប់រហ័ស។ ពួកគេបានចូលទៅក្នុងផ្ទះស្ត្រីម្នាក់ឈ្មោះរ៉ាហាប។ រ៉ាហាបបានដឹងថាព្រះគឺជាមិត្តរបស់អ្នកស៊ើបការណ៍ទាំងពីរនាក់នោះ។ នាងបានដឹងថាព្រះមានអំណាចខ្លាំងជាងអ្នកណាៗទាំង-អស់។ ដូច្នេះនៅពេលដែលទាហានដែលជាសត្រូវរបស់អ្នកស៊ើបការមកដល់ផ្ទះរបស់នាង ដើម្បីសម្លាប់ពួកគេ រ៉ាហាបបានចាត់ការធ្វើរឿងមួយយ៉ាងរហ័ស។ នាងបានលាក់ពួកគេនៅលើដំបូលផ្ទះរបស់នាង។ ធ្វើឲ្យពួកទាហានមិនអាចរកអ្នកស៊ើបការទាំងពីរនាក់នោះឃើញទេ!

ចុងក្រោយពួកទាហានក៏បានចាកចេញទៅ។ រ៉ាហាបបាននិយាយទៅកាន់អ្នកស៊ើបការនោះថា "ខ្ញុំដឹងថា ព្រះយេហូវ៉ាបានប្រទានស្រុកនេះដល់អ្នករាល់គ្នាហើយ មួយទៀតសេចក្តីស្ញែងខ្លាចរបស់អ្នករាល់គ្នាបាន ធ្លាក់មកលើយើងដែរ" (**យ៉ូស្វេ ២៖៩**)។ រ៉ាហាបបានសុំអ្នកស៊ើបថា "ដូច្នេះ ខ្ញុំសូមអង្វរអ្នក សូមស្បថ នឹង ខ្ញុំឥឡូវ ដោយនូវព្រះយេហូវ៉ាថា អ្នករាល់គ្នានឹងអាណិតមេត្តាដល់ពួកគ្រួឪពុកខ្ញុំ ដូចជាខ្ញុំបានអាណិត មេត្តាដល់អ្នកដែរ សូមប្រាប់ទីសំគាល់ដ៏ប្រាកដច្បាស់មកខ្ញុំផង ឲ្យខ្ញុំដឹងថា អ្នករាល់គ្នានឹងទុកជីវិតដល់ ឪពុកម្តាយ និងបងប្អូនរបស់ខ្ញុំ ព្រមទាំងវង្សាគាត់ដែរ ដោយជួយដោះយើងខ្ញុំឲ្យរួចពីស្លាប់" (**យ៉ូស្វេ ២៖១២-១៣**)។

អ្នកស៊ើបបានយល់ព្រមថា នឹងការពាររ៉ាហាប។ អ្នកស៊ើបបានឲ្យខ្សែក្រហមទៅរ៉ាហាប ពួកគេបានប្រាប់នាងឲ្យព្យួរខ្សែក្រហមនោះនៅត្រង់បង្អួចផ្ទះរបស់នាង ដូច្នេះពួកគេនិងស្គាល់ថាផ្ទះមួយណាជាផ្ទះរ៉ាហាប អ្នកស៊ើបការនិយាយថា ពួកគេនិងការពារផ្ទះរបស់នាង។ រ៉ាហាបជឿជាក់ ហើយទុកចិត្តព្រះ។ រ៉ាហាបស្ម័គ្រចិត្តជួយអ្នកដទៃនាងមានចិត្តស្មោះត្រង់។ ព្រះក៏ចង់ឲ្យយើងស្មោះត្រង់ផងដែរ។ ភាពស្មោះត្រង់របស់យើងធ្វើឲ្យព្រះសប្បាយព្រះទ័យ។

## ៦. សំនួរពិភាក្សា

១. តើមានអ្នកស៊ើបការប៉ុន្មាននាក់ដែលយ៉ូស្វេបានបញ្ជូនទៅ?( *ពីរ*)

២. តើអ្នកស៊ើបការត្រូវបានបញ្ជូនទៅស៊ើបនៅទីក្រុងឈ្មោះអ្វី?( *ទីក្រុងយេរីខូរ*)

៣. តើរ៉ាហាបបានធ្វើអ្វីចំពោះអ្នកស៊ើបការនោះ? ( *នាងបានការពារពួកគេដោយការលាក់ពួកគេពីសត្រូវ*)

៤. ហេតុអ្វីបានជារ៉ាហាបជួយលាក់អ្នកស៊ើបការនោះ? ( *ពីព្រោះនាងមានក្តីជំនឿលើព្រះ*)

៥. តើប្អូនអាចបង្ហាញសេចក្ដីជំនឿរបស់ប្អូនចំពោះព្រះដោយរបៀបណា? ( *ទុកឲ្យកុមារឆ្លើយ*)

## ៧. ល្បែងកំសាន្ត «បិទពួន»



១. រ៉ាហាបបានព្យាយាមលាក់អ្នកស៊ើបការពីពួកទាហាន។ សូមជ្រើសរើសយកកុមារ២នាក់ ហើយឲ្យកុមារម្នាក់យកកុមារម្នាក់ទៀតក្នុងចំណោមពួកគេទៅពួននៅកន្លែងដែលបានរៀបចំទុកជាស្រេច (សូមកំណត់ទីតាំងដែលត្រូវលេងល្បែងនេះ)

២. ពេលដែលកុមារបានរៀបចំពួនរួចរាល់ហើយ គ្រូឲ្យកុមារដទៃៗទៀតដើររកកុមារម្នាក់ដែល កំពុងពួន ដូចជាទាហានដើររកពួកអ្នកស៊ើបការអីចឹងដែរ។

៣. សូមលែងល្បែងនេះ ម្តងហើយម្តងទៀតជាមួយក្មេងៗដទៃទៀត។

## ៨. ខគម្ពីរចងចាំ

**ហេព្រើ ១១៖៦** *“តែបើឥតមានសេចក្ដីជំនឿទេ នោះមិនអាចនឹងគាប់ដល់ព្រះហឫទ័យព្រះបានឡើយ ដ្បិតអ្នកណាដែលចូលទៅឯព្រះ នោះត្រូវតែជឿថា មានព្រះមែន ហើយថាទ្រង់ប្រទានរង្វាន់ដល់អស់អ្នកដែលស្វែងរកទ្រង់”។*

## ៩. ហត្ថកម្ម

ឲ្យកុមារផាត់ពណ៌ លើរូបភាព “រ៉ាហាបជួយសង្គ្រោះអ្នកស៊ើបការ” ។

## ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១២. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
តើអ្នកនឹងនៅទីណាដោយគ្មានវត្តមានរបស់ព្រះយេស៊ូវនៅក្នុងជីវិតរបស់អ្នក? សូមចំណាយពេលបន្តិចដើម្បីសញ្ជឹងគិតអំពីចម្លើយចំពោះសំណួរនោះ។ តើព្រះបានធ្វើការអស្ចារ្យអ្វីខ្លះ ដើម្បីនាំអ្នកទៅកន្លែងដែលអ្នកនៅសព្វថ្ងៃ? តើការអស្ចារ្យទាំងនោះកើតឡើងដោយរបៀបណា? តើមានអ្នកណាខ្លះដែលមានវត្តមានក្នុងការអស្ចារ្យនោះ? តើនៅក្នុងកាលៈទេសៈអ្វី? តើអ្នកបានចាប់អារម្មណ៍ទេថា មានការអស្ចារ្យមួយបានកើតឡើងនៅពេលនោះ? ចូរអរសប្បាយដោយដឹងថារូបអ្នកត្រូវបាន ប្រើប្រាស់ដើម្បីធ្វើជាឱកាសក្នុងការបង្ហាញពីការអស្ចារ្យរបស់ព្រះជាម្ចាស់ នៅក្នុងជីវិតរបស់អ្នកដទៃដូចជាតាមរយៈការបង្រៀនកុមារអំពីព្រះនៅថ្ងៃនេះផងដែរ។

# រ៉ាហាបជួយសង្គ្រោះអ្នកស៊ើបការ



សូមសរសេរខគម្ពីរចងចាំ៖_______________________

_______________________

_______________________

_______________________

_______________________

_______________________